# មេរៀនទី ៤ ៖ ការដាក់ផែនការការបម្រើ និងសកម្មភាពនានា

*អ្នកអាចបង្រៀនមេរៀននេះម្ដងទាំងអស់ ឬបែងចែកវាជាផ្នែកខ្លីៗដាងនេះ ។ សូមសម្របមេរៀននេះតាមកាលៈទេសៈក្នុងមូលដ្ឋានរបស់អ្នក និងតាមតម្រូវការ តាមអាយុ ព្រមទាំងតាមការយល់ដឹងរបស់គណៈប្រធានកូរ៉ុម ឬថ្នាក់របស់អ្នក ។*

## ការបម្រើ និងសកម្មភាពនានាអាចជួយយើងឲ្យធ្វើតាមព្រះអង្គសង្គ្រោះបាន

នៅក្នុងយុវវ័យរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ « ក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង » ( លូកា ២:៥២ ) ។ សូមឲ្យសមាជិកគណៈប្រធានកូរ៉ុម និងថ្នាក់ពិភាក្សាគ្នាពីមូលហេតុដែលការបម្រើ និងសកម្មភាពនានាគឺជារឿងសំខាន់ ។ តើការបម្រើ និងសកម្មភាពអាចជួយយើងឲ្យកាន់តែក្លាយដូចជាព្រះអង្គសង្គ្រោះដោយរបៀបណា ?

## យើងអាចសម្រេចបានកិច្ចការរបស់ព្រះអម្ចាស់តាមរយៈការដាក់ផែនការដែលមានគោលបំណង

សូមអញ្ជើញសមាជិកគណៈប្រធានពិនិត្យមើលឡើងវិញនូវគោលការណ៍ដែលមាននៅក្នុង សេចក្ដីណែនាំអំពីសកម្មភាព និងការបម្រើសម្រាប់យុវវ័យ ។ សូមឲ្យពួកគេប្រើ សៀវភៅផែនការការបម្រើ និងសកម្មភាព ដើម្បីជួយពួកគេឲ្យកត់ត្រាយោបល់ពីរបីដែលអនុវត្តតាមគោលការណ៍ទាំងនោះ ។ សូមឲ្យពួកគេដាក់ផែនការលម្អិតលើសកម្មភាពទាំងនោះមួយដោយប្រើ ផែនការលម្អិតស្ដីពីការបម្រើ និងសកម្មភាព ។ នៅក្នុងការប្រជុំគណៈប្រធាននៅពេលខាងមុខ សូមឲ្យពួកគេពិនិត្យមើលឡើងវិញនូវសកម្មភាពទាំងឡាយដែលពួកគេបានមាន ហើយមើលថាតើវាបានជោគជ័យប៉ុណ្ណាដែរ ដោយយោងតាមគោលការណ៍នៅក្នុង សេចក្ដីណែនាំអំពីសកម្មភាព និងការបម្រើសម្រាប់យុវវ័យ ។

## ធនធានគាំទ្រ

- យោបល់សម្រាប់ការបម្រើ និងសកម្មភាពនានាមាននៅលើគេហទំព័រ ChildrenandYouth.ChurchofJesusChrist.org

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2020 by Intellectual Reserve, Inc. All rights reserved. 4/20. ការបកប្រែនៃ *Quorum and Class Presidency Training - Lesson 4* ។
Cambodian. PD60011122 258. បោះពុម្ពនៅសហរដ្ឋអាមេរិក